Healthcare for All Kids

## តើ All Kids ជាអ្វី?

កម្មវិធី All Kids របស់អភិបាល Blagojevich គឺជាកម្មវិធីថែទាំសុខភាពពេញលេញ សម្រាប់រាល់កុមារទាំងអស់ដែលមិនមានការធានារ៉ាប់រងនៅក្នុងរដ្ឋ Illinois ។ Illinois គឺជារដ្ឋដំបូងក្នុងប្រទេស ដែលធានាថារាល់កុមារទាំងអស់ដោយមិនគិតពីស្ថានភាពសុខភាព ឬ ប្រាក់ចំណូល មានសិទ្ធទទួលនូវការថែទាំសុខភាពគ្រប់គ្នា ។

## តើ All Kids ធានារ៉ាប់រងលើអ្វីខ្លះ ?

All Kids ធានារ៉ាប់រងលើការថែទាំសុខភាពទាំងអស់ ដែលកុមារអាចត្រូវការ ។ All Kids បង់ចំណាយសម្រាប់ការទៅជួបជាមួយវេជ្ជបណ្ឌិត ការទៅមន្ទីរពេទ្យ ការថែទាំធ្មេញ ការថែទាំភ្នែក ការទិញថ្នាំតាមវេជ្ជបញ្ជា បរិក្ខារសុខភាព សេវាកម្មសុខភាពផ្លូវចិត្ត និង សេវាកម្មជាច្រើនផ្សេងទៀត ។

## តើមានសេចក្តីផ្អែកប្រាក់ចំណូលយ៉ាងដូចម្តេច ?

សម្រាប់ All Kids មិនមានការកំណត់ចំពោះប្រាក់ចំណូលដែលគ្រួសារណាមួយអាចរកបាននោះទេ ។

## តើវាដំណើរការទៅយ៉ាងដូចម្តេច ?

All Kids នឹងធ្វើឱ្យគ្រួសារភាគច្រើនបំផុតចំណាយអស់តិចបំផុតជាងការធានារ៉ាប់រងឯកជន ។ ជាឧទាហរណ៍ គ្រួសារមួយ ដែលមានសមាជិកបួននាក់ ដែលរកបានចំណូលបាន ៥0 000 ដុល្លារក្នុងមួយឆ្នាំ នឹងបង់ ៤0 ដុល្លារ ក្នុងមួយខែ សម្រាប់កូនម្នាក់ និង ៨0 ដុល្លារ សម្រាប់កូនចាប់ពីពីរនាក់ឡើងទៅ បូកនឹងការបង់ថ្លៃចូលរួម(co-pay)ចំនួន ១0 ដុល្លារ សម្រាប់ការទៅជួបវេជ្ជបណ្ឌិតម្តងៗ ។ គ្រួសារដែលមានសមាជិកបួននាក់ដែលអាចរកបានចំណូលបាន ២៩ 000 ដុល្លារ ក្នុងមួយឆ្នាំ មិនមាននូវការចំណាយប្រចាំខែទេ ហើយបង់ថ្លៃចូលរួម(co-payment)ចំនួន ២ ដុល្លារ សម្រាប់ការទៅជួបវេជ្ជបណ្ឌិតម្តងៗ ។

All Kids មាននូវការកំណត់ប្រចាំឆ្នាំចំពោះការបង់ចំណាយរួម(co-pays)សរុប ដែលគ្រួសារភាគច្រើនបំផុតត្រូវបង់សម្រាប់ការថែទាំសុខភាពកូនរបស់ពួកគេ ។ ការបង់ថ្លៃសរុបចំពោះគ្រួសារនីមួយៗ ខុសគ្នាអាស្រ័យទៅតាមប្រាក់ចំណូល ។

## តើនរណាដែលមានសិទ្ធិទទួល ?

កុមារដែលមានអាយុ ១៨ ឆ្នាំ ឬតិចជាងនេះ ដែលរស់នៅជាមួយគ្រួសាររបស់ពួកគេនៅក្នុងរដ្ឋ Illinois ហើយចង់បាននូវការធានារ៉ាប់រងសុខភាព អាចទទួលបាននូវ All Kids ។

## តើមានអ្វីកើតឡើងចំពោះ KidCare ?

កម្មវិធី KidCare របស់រដ្ឋ Illionis ឥឡូវនេះគឺជាផ្នែកមួយរបស់ All Kids ហើយ! ប្រសិនបើលោកអ្នកមាន KidCare នោះកូនរបស់លោកអ្នកនឹងទទួលបាននូវ All-Kids ជាស្វ័យប្រវត្តិ ។ លោកអ្នកមិនចាំបាច់ដាក់ពាក្យសុំជាថ្មីនោះទេ ។

1-866-ALL-KIDS
(1-866-255-5437 Voice) (1-877-204-1012 TTY)
www.allkidscovered.com

ROD R. BLAGOJEVICH
GOVERNOR, STATE OF ILLINOIS